# ខៀវ សំផន ស្នើសុំតុលាការនៅក្រៅឃុំដោយសារ ភាពយឺតយាវនីតិវិធីជំនុំជម្រះសេចក្តី

**ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៣**

លឹម ជ័យទ័ត្ត
អ្នកសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម,
មជ្ឈមណ្ឌលឯកសារកម្ពុជា

នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន បានដាក់សំណើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដោះលែង ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់ ដោយអះអាងថា រយៈពេលដែលតុលាការចាប់កូនក្តីរបស់ខ្លួនមកឃុំឃាំងបណ្តោះអាសន្នមានរយៈពេលយូរហួសហេតុ ដែលអាចនាំទៅជាការរំលោភសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ ។

ក្រុមមេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់នៅក្នុងសំណើរបស់ខ្លួនថា បើផ្អែកលើស្ថានភាពបច្ចុប្បន្ន ការជំនុំជម្រះក្តីលើរូប ខៀវ សំផន មិនឆាយនឹងបញ្ចប់នោះទេ ដោយសារការលុបចោលដីកាបំបែកកិច្ចដំណើរការនីតិវិធីបានធ្វើឲ្យប៉ះពាល់ដល់ភាពឆាប់រហ័សនៃការជំនុំជម្រះក្តី ហើយលទ្ធភាពនៃការចេញសាលក្រមសម្រាប់រឿងក្តីនេះទៀតសោត ក៏ហាក់បីដូចជានៅស្ថិតឆ្ងាយពីការរំពឹងទុកនៅឡើយ ។ ក្រុមមេធាវីការពារក្តីបានលើកឡើងទៀតថា រហូតមកដល់ពេលនេះ ខៀវ សំផន បានស្ថិតនៅក្នុងមន្ទីរឃុំឃាំងអស់រយៈ៥ឆ្នាំ ៤ខែ ដោយពុំទាន់មានសាលក្រមជំនុំជម្រះសេចក្តី ហេតុនេះល័ក្ខខ័ណ្ឌដែលបញ្ជាក់អំពីការបន្តឃុំខ្លួនបណ្តោះអាសន្ន មិនត្រូវបានបំពេញទៀតឡើយ ។ ដូច្នេះ ខៀវ សំផន គួរតែត្រូវបានដោះលែង ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការវិញ ។

នៅក្នុងអំឡុងពេលនៃសវនាការស្តីពីការពិចារណាលើផលវិបាកដែលកើតចេញពីសេចក្តីសម្រេចលុបចោលដីកាបំបែកសំណុំរឿង០០២ កាលពីខែកុម្ភៈ ឆ្នាំ២០១៣កន្លងទៅ ក្រុមមេធាវីការពារក្តី ខៀវ សំផន ធ្លាប់បានស្នើសុំអង្គជំនុំជម្រះឲ្យដោះលែង ខៀវ សំផន ម្តងរួចទៅហើយ ដោយនៅពេលនោះក្រុមមេធាវីការពារក្តីបានបញ្ជាក់ថា ខៀវ សំផន ត្រូវការឲ្យមានការជំនុំម្រះដោយឆាប់រហ័សមកលើរូបខ្លួន ដោយសារខ្លួនត្រូវការជួបជុំជាមួយនឹងប្រពន្ធកូន នៅពេលដែលអង្គជំនុំជម្រះពុំអាចរកឃើញអំពីពិរុទ្ធភាពរបស់ខ្លួន ។ ម្យ៉ាងវិញទៀត ស្ថានភាពសុខភាពរបស់ ខៀវ សំផន មិនដូចនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទដទៃទៀតឡើយ ព្រោះ ខៀវ សំផន អាចចូលរួមក្នុងសវនាការជាង៩៩ភាគរយដោយបង្ហាញមុខគ្រប់ពេលវេលាដើម្បីទទួលបានការជំនុំជម្រះ និងស្វែងរកយុត្តិធម៌សម្រាប់ខ្លួន ។ ខៀវ សំផន បានអះអាងថា ការដែលសវនាការជំនុំជម្រះសេចក្តីមកលើរូបខ្លួនត្រូវបានពន្យាពេលដោយសារ

តែបញ្ហាសុខភាពរបស់ជនជាប់ចោទផ្សេងនោះ គឺអាចនឹងប៉ះពាល់សិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស ដោយសារខ្លួនត្រូវជាប់ឃុំដោយពុំទទួលបានការជំនុំជម្រះ នៅខណៈពេលដែលខ្លួនអាចចូលរួមសវនាការបាន ។

ចាប់តាំងពីត្រូវបានចាប់ខ្លួន និងបញ្ជូនមកឃុំខ្លួនបណ្ដោះអាសន្ននៅមន្ទីរឃុំឃាំងរបស់សាលាក្ដីខ្មែរក្រហមនៅខែវិច្ឆិកា ឆ្នាំ២០០៧ ខៀវ សំផន ធ្លាប់បានស្នើសុំតុលាការឲ្យដោះលែងរូបខ្លួនចំនួន៤លើករួចមកហើយ ប៉ុន្តែសំណើទាំងនោះ គឺត្រូវបានបដិសេធទាំងអស់ ។ ការបដិសេធទាំងអស់នេះ ត្រូវបានតុលាការផ្ដល់ហេតុផលថា ការដោះលែងជនជាប់ចោទ ខៀវ សំផន ឲ្យនៅក្រៅឃុំបណ្ដោះអាសន្នអាចនឹងបង្កឲ្យមានហានិភ័យមួយចំនួនដូចជា ហានិភ័យនៃការប៉ះពាល់ដល់លទ្ធភាពចេញសាលក្រមក្នុងរយៈពេលសមស្រម, ហានិភ័យចំពោះសណ្ដាប់ធ្នាប់សាធារណៈ, ហានិភ័យចំពោះសុវត្ថិភាពរបស់ ខៀវ សំផន និងហានិភ័យនៃកង្វះការថែទាំវេជ្ជសាស្ត្រសមស្របនៅពេល ខៀវ សំផន ត្រូវការ ។ ប៉ុន្តែ ខៀវ សំផន បានចាត់ទុកការបន្តឃុំរូបខ្លួននៅក្នុងមន្ទីរឃុំឃាំងថាជាការមិនសមស្រប មិនចាំបាច់ និងហួសហេតុ ។

ខៀវ សំផន ត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវតាមរយៈការធ្វើសកម្មភាព ឬបរាជ័យក្នុងការទប់ស្កាត់ បញ្ជា ញុះញង់ រៀបចំផែនការ ដឹកនាំ ឬសមគំនិត ដោយការជួយជំរុញ ឬបង្កលក្ខណៈងាយស្រួលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ បទឧក្រិដ្ឋទាំងនោះរួមមាន ៖

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ៖ មនុស្សឃាត ការសម្លាប់ផ្ដាច់ពូជ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត ។

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ៖ ការសម្លាប់រង្គាលក្រុមជនជាតិវៀតណាម និងចាម ។

ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩៖ មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការប្រព្រឹត្តអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រូបរាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ក្ដីដោយយុត្តិធម៌ ការបង្ខាំង និងការនិរទេសជនស៊ីវិលដោយខុសច្បាប់ ។

ប៉ុន្តែ ខៀវ សំផន បានបដិសេធរាល់ការចោទប្រកាន់ទាំងអស់ និងថា ខ្លួនពុំបានដឹងអំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ហើយនៅក្នុងរបបនោះខ្លួនក៏ពុំមានសិទ្ធិអំណាចក្នុងការធ្វើសេចក្ដីសម្រេចអ្វីទាំងអស់ ។

នៅក្នុងតុលាការ ខៀវ សំផន ធ្លាប់បានឡើងអះអាងថា ខ្លួនសង្ឃឹមថាសវនាការនេះ គឺអាចជាឱកាសល្អមួយសម្រាប់ឲ្យខ្លួនបានពន្យល់ដល់ប្រជាជនកម្ពុជាឲ្យយល់ថា ហេតុម្តេចបានជាខ្លួនដែលជាអ្នកកាន់ដំណែងមួយខ្ពស់ជាផ្លូវការក្នុងរបបកម្ពុជាប្រជាធិបតេយ្យហើយ នៅតែថាមិនដែលបានចូលរួមសម្រេចកិច្ចការអ្វីធំដុំ និងមិនបានដឹងអំពីអ្វីដែលបានកើតមាននៅក្នុងប្រទេសកម្ពុជានៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ ។ ខៀវ សំផន បានបង្ហាញពីការសន្យារបស់ខ្លួនថាៈ

*"ខ្ញុំបានសន្យាជាមួយបងប្អូនជនរួមជាតិហើយថា ខ្ញុំនឹងព្យាយាមគោរពតាមពាក្យសន្យានោះ ។ នេះជាការងារមួយលំបាកសម្រាប់ខ្ញុំ តែខ្ញុំមានជំនឿជឿជាក់ថា ដំណើរការតុលាការកាន់តែឈានទៅមុខជាបណ្តើរៗទៅ ព្រះសង្ឃ និងបងប្អូនជនរួមជាតិនឹងឃើញ និងអាចវិនិច្ឆ័យបានដោយខ្លួនឯងផ្ទាល់" ។*

ខៀវ សំផន ធ្លាប់បានបញ្ជាក់អំពីជំហររបស់ខ្លួននៅក្នុងសវនាការបឋមកាលពីថ្ងៃទី២៧-៣០ ខែមិថុនា ឆ្នាំ២០១១ ថា ខ្លួននឹងសហការជាមួយនឹងតុលាការឲ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីធ្វើឲ្យលេចចេញនូវការពិតដែលកើតមាននៅរវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ។

នៅក្នុងសវនាការថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ខៀវ សំផន ស្រាប់តែបង្ហាញអំពីជំហរផ្ទុយពីអ្វីដែលខ្លួនធ្លាប់បានលើកឡើង ដោយអះអាងថា ខ្លួននឹងពុំឆ្លើយតបនឹងសំណួរទាំងឡាយរបស់ភាគីនៅក្នុងសវនាការដែលចោទសួរមកលើខ្លួនឡើយ លុះត្រាតែសហព្រះរាជអាជ្ញាបានបង្ហាញភស្តុតាងដែលចោទប្រកាន់មកលើខ្លួនជាមុនសិន ។ ខៀវ សំផន មានសិទ្ធិអាចនៅស្ងៀម ដោយពុំចាំបាច់ឆ្លើយតបនឹងសំណួររបស់ភាគីណាមួយបាន ដោយសារនេះជាគោលការណ៍ដែលមានចែងនៅក្នុងច្បាប់ ដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ ។ រហូតមកទាល់នឹងពេលបច្ចុប្បន្ននេះ ខៀវ សំផន នៅតែបន្តពុំទាន់បានឆ្លើយតបនឹងសំណួរទាំងឡាយដែលភាគីបានចោទសួរមកលើរូបខ្លួន ដោយអះអាងថា ខ្លួននឹងយល់ព្រមឆ្លើយតបនឹងសំណួរ ប្រសិនបើសហព្រះរាជអាជ្ញាបានបង្ហាញភស្តុតាងទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់មកលើរូបខ្លួន ។